ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សាលក្រមព្រហ្មទណ្ឌ

លេខ: ១០៧ (ង)

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៤៨

ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ: ១១១៣

ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ: ១៤៦៤

ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅថ្ងៃចន្ទ ១២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ២.៣០ នាទី រសៀល នៅសាលសវនាការលេខ: ៣ អគារ (B) ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៤៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ឆាត់** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ មុខរបរ ទាហាន សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី៧ ចាស់ ឪពុកឈ្មោះ [redacted] **អាយ** (ស) ម្តាយឈ្មោះ [redacted] **ឡុក** (ស) ប្រពន្ធឈ្មោះ [redacted] **សាភេន** មានកូនចំនួន០៥ នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

**លោក** [redacted] ជាមេធាវីការពារសិទ្ធិ និងលោកមេធាវី [redacted] ជាគ្រូកម្មសិក្សា។

២-ឈ្មោះ [redacted] **ភ្លន់** ភេទប្រុស អាយុ៦៤ ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើស្រែ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ មិនចេះអក្សរ ឪពុកឈ្មោះ[redacted] **ឈឿង** (ស) ម្តាយឈ្មោះ[redacted] **យុន** (រ) ប្រពន្ធឈ្មោះ[redacted] **អ៊ិត** មានកូនចំនួន០៦ នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

**លោក**[redacted] ជាមេធាវីការពារសិទ្ធិ។

៣-ឈ្មោះ [redacted] **ឡើត** ភេទប្រុស អាយុ៥៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើស្រែ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១០ ចាស់ ឪពុក



Scanned with CamScanner

ឈ្មោះ [redacted] នឿត (ស) ម្ដាយឈ្មោះ [redacted] ខន (រ) ប្រពន្ធឈ្មោះ [redacted] យឿន មានកូនចំនួន០៥ នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

លោក [redacted] ជាមេធាវីការពារសិទ្ធិ។

៤-ឈ្មោះ [redacted] **យឿត** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន នៅភូ[redacted]ខេត្តសៀមរាប។ (គ្មានខ្លួន)

៥-ឈ្មោះ [redacted] **ប៉ូឡាស់** ភេទប្រុស អាយុ៤៧ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តសៀមរាប។ (គ្មានខ្លួន)

៦-ឈ្មោះ [redacted] **ផៃ** ភេទប្រុស អាយុ៤២ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប។ (គ្មានខ្លួន)

ត្រូវជាប់ចោទពីបទ: **ឆបោក** ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឆន** ភេទប្រុស អាយុ៥៧ ឆ្នាំ ជនជាតិខ្មែរ (ទាមទារការខាតបង់ប្រាក់ចំនួន **២៦៦ ៣៨៣ (ម្ភៃប្រាំមួយម៉ឺន ប្រាំមួយពាន់បីរយប៉ែតសិបបី)** ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន **១០០.០០០ (ដប់ម៉ឺន) ដុល្លាអាមេរិក។**

**លោក** [redacted] **ជាមេធាវីការពារសិទ្ធិ។**

បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ: ១២៦៧ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

បានឃើញ: ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៦៨៨៧ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២២៣៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០០៨ ឈ្មោះ [redacted] ឆន បានទិញដីពីឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ ចំនួន២២១ (ពីររយម្ភៃមួយ) ហិចតា មានទីតាំងស្ថិតនៅភូមិសំបួរ ភូមិអំពិល ភូមិគោកចាស់ និងភូមិសន្លន ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលក្នុងមួយហិចតាមានតម្លៃ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ហើយឈ្មោះ [redacted] ឆន បានប្រគល់ប្រាក់ឱ្យទៅឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ ចំនួន៣៧៥,១៨៣ (សាមសិបប្រាំពីម៉ឺន ប្រាំពាន់មួយរយប៉ែតសិបបី) ដុល្លាអាមេរិក គ្រប់ចំនួនថ្លៃដីទាំងអស់។ នៅពេលធ្វើការទិញដីនោះឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ បាននាំឈ្មោះ [redacted] ឆន ទៅមើលទីតាំងដី និងបានបង្ហាញនូវគំនូសរូបរាងដី និងគណាក្រឡាផ្ទៃស្ថិតនៅភូមិសន្លន, ភូមិគោកចាស់, ឃុំអំពិល ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលវាស់វែងដោយលោក [redacted] គឹមសាន ចុះថ្ងៃទី២៣ ខែកក្កដា

ឆ្នាំ២០១៨ មានចំនួន២ប្លង់ និងមានឯកសារផ្ទេរសិទ្ធិដីមួយចំនួន។ បន្ទាប់មកទៀតឈ្មោះ [redacted] ឆន បានទាមទារឱ្យឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ ធ្វើការបង្ហាញទីតាំងជាក់ស្តែងតែពួកគេពុំព្រមនាំឈ្មោះ [redacted] ឆន ទៅមើលនោះឡើយ ដោយសន្យាថ្ងៃនោះរហូត ហើយឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ បានប្រគល់ដីឱ្យទៅឈ្មោះ [redacted] ឆន បានតែ៦៤ (ហុកសិបបួន) ហិចតា តែប៉ុណ្ណោះនៅខ្វះដីចំនួន១៥៧ (មួយរយហាសិបប្រាំពីរ) ហិចតា ដែលឈ្មោះ [redacted] ឆាក់, ឈ្មោះ [redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់, ឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ភ្លន់ ពុំមានដីប្រគល់ឱ្យទៅឈ្មោះ [redacted] ឆន រហូតដល់សព្វថ្ងៃ។

## **នាពេលសវនាការ**

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឆាក់ បានឆ្លើយថា: [redacted] ឆន គាត់ទៅទិញដីនៅស្រុកក្រឡាញ់ ខ្លួនជាអ្នកបើកបរឡានជូនគាត់ទៅតាមកន្លែងដែលគាត់ទិញដី ហើយរាល់ការវាស់វែងដី ខ្លួនមិនបានដឹងទេគឺខ្លួននៅចាំឡាន ដោយឈ្មោះ [redacted] ឆន (ជាទាហ៊ាន) ហើយជួលកាលខ្លួនជាអ្នកធ្វើ សាក្សីដឹងលឺពីការទិញលក់ដីនោះដែរ។ ចំពោះការជូនឈ្មោះ [redacted] ឆន ទៅទិញដីគឺគាត់បានឱ្យខ្លួនចំនួន២០ (ម្ភៃ) ទៅ ៣០ (សាមសិប) ដុល្លាអាមេរិក សម្រាប់ចាក់សាំង។ ខ្លួនស្គាល់ឈ្មោះ [redacted] ភ្លន់ ពីព្រោះធ្លាប់ទៅហូបបាយនៅផ្ទះគាត់នៅពេលដែលទៅទិញដី ចំណែកឯឈ្មោះ [redacted] ប៉ូឡាស់ ឈ្មោះ [redacted] ផៃ គាត់ជាអ្នកណែនាំឈ្មោះ [redacted] ឆន ទៅទិញដីនៅស្រុកក្រឡាញ់ នៅពេលនោះក៏មានការទិញដីពីអ្នកស្រុកក្រឡាញ់ពេលខ្លះឈ្មោះ [redacted] ឆន បានឱ្យខ្លួនផ្តិតមេដៃជាសាក្សីដឹងលឺ ហើយរាល់ការប្រគល់ប្រាក់ទិញឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ប៉ូឡាស់ ជាអ្នកទទួលប្រាក់ពីឈ្មោះ [redacted] ឆន ហើយយកប្រាក់នោះទៅប្រគល់បន្តឱ្យទៅអ្នកលក់។ មូលហេតុដែលខ្លួនព្រមផ្តិតមេដៃធ្វើជាសាក្សី ឬអ្នកដឹងលឺដោយសារតែឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ប៉ូឡាស់ គាត់បានសន្យាឱ្យចំណែក១០% នៃកំរៃជើងសារចំណែកឯឈ្មោះ [redacted] ភ្លន់ ក៏បានទទួលចំណែក១០% ដូចខ្លួនដែរ ប៉ុន្តែខ្លួនមិនដែលទទួលបានប្រាក់ចំនួន១០% ម្តងណាឡើយ រហូតដល់ពេលនេះ។ មូលហេតុដែលខ្លួនស្គាល់ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ប៉ូឡាស់ ដោយសារឈ្មោះ [redacted] ប៉ូឡាស់ កាលពីមុនគាត់គឺជាស្មៀន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ រាល់ការទិញលក់ខ្លួនបានត្រឹមធ្វើជាដឹងលឺ ឬជាសាក្សីចំណែក កាលប្រគល់ប្រាក់ខ្លួនមិនដែលឃើញនោះទេ។ ចំពោះលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៨ ខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ឃន ចំនួន៤០០០ (បួនពាន់) ដុល្លាអាមេរិក ហើយខ្លួនបានយកប្រាក់នោះទៅឱ្យឈ្មោះ [redacted] ប៉ូឡាស់ ដើម្បីទិញដីចំនួន៥ហិចតា ឱ្យទៅឈ្មោះ [redacted] ឃន មូលហេតុដែលឈ្មោះ [redacted] ឃន ឱ្យប្រាក់ខ្លួនទៅទិញដីជំនួសគាត់ដោយសារតែឈ្មោះ [redacted] ឃន ជាប់រវល់ និងការងារធ្វើសំណង់ទើបគ្មានពេលវេលាទៅទិញ។ ចំពោះលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៨ នៅក្នុងនោះលិខិតនោះមានស្នាមមេដៃខ្លួនទទួលប្រាក់ចំនួន១០០០០ (មួយម៉ឺន) ដុល្លាអាមេរិក ខ្លួនមិនចាំច្បាស់ទេព្រោះយូរឆ្នាំមកហើយ ប៉ុន្តែខ្លួននៅចាំថាពុំដែលបានទទួលលុយនោះទេ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភ្លន់ បានឆ្លើយថា: កាលពីមុនខ្លួនមិនស្គាល់ឈ្មោះ [redacted] ឆន នោះទេ ក្រោយមកឈ្មោះ [redacted] ឆន គាត់បានឱ្យក្រុមការងារគាត់ចុះទៅទិញដីនៅភូមិអំពិល ឃុំសំបួរ

ស្រុកក្រឡាញ់ ខេត្តសៀមរាប មិនដឹងចំនួនពិតប្រាកដ ក្រោយមកឈ្មោះ [redacted] ប៊ូឡាស់ ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ ដែលជាក្រុមការងារចុះទិញដីរបស់ឈ្មោះ [redacted] ឆន ពួកគាត់បាននិយាយថាប្អូនរស់នៅភូមិនេះមានស្គាល់ដីណាលក់ទេ ខ្លួនឆ្លើយថាខ្លួនស្គាល់ម្ចាស់ដី។ បន្ទាប់មកខ្លួនបានទៅសួរប្រជាពលរដ្ឋរស់នៅក្នុងភូមិដែលឈ្មោះ [redacted] ឆន ចង់ទិញដី ហើយប្រជាពលរដ្ឋបានសួរខ្លួនវិញថាបងចង់ទិញមួយហិចតាតម្លៃប៉ុន្មាន ខ្លួនឆ្លើយវិញថាខ្លួនមិនដឹងតម្លៃទេ បើចង់លក់ឱ្យចុះទៅជួបអ្នកទិញទៅ។ ក្រោយមកប្រជាពលរដ្ឋបាននាំគ្នាទៅសួរនាំនឹងលក់ដោយខ្លួនគាត់ផ្ទាល់ ហើយខ្លួនក៏បានលក់ដីដោយផ្ទាល់ខ្លួនដែរចំនួន៤ (បួន) ហិចតា នៅកន្លែងផ្សេងៗគ្នាតម្លៃ១ (មួយ) ហិចតា១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក និងកន្លែងខ្លះ១ (មួយ) ហិចតា តម្លៃ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លាអាមេរិក ដោយខ្លួនបានទទួលលុយគ្រប់ចំនួនពីមេភូមិ និងក្រុមការងារចុះទិញដីមានឈ្មោះ [redacted] ប៊ូឡាស់, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ ។ ខ្លួនធ្លាប់បានជួបឈ្មោះ [redacted] ឆន ម្តង ដោយទៅជាមួយក្រុមការងារគាត់មានឈ្មោះ [redacted] ប៊ូឡាស់, ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ ។ ខ្លួនមិនបាននិយាយជាមួយឈ្មោះ [redacted] ឆន នោះទេ ហើយឈ្មោះ [redacted] ឆន ក៏មិនបាននិយាយអ្វីមកកាន់ខ្លួនដែរ ខ្លួនស្គាល់ឈ្មោះ [redacted] ឆន ដោយសារក្រុមការងារគាត់និយាយប្រាប់ទើបស្គាល់មុខនិងឈ្មោះ ពីព្រោះមិនហ៊ាននៅក្បែរឈ្មោះ [redacted] ឆន នោះទេ ដោយសារគាត់ជាអ្នកធំ។ ចំពោះលុយកាក់ទិញដីគាត់មិនដឹង ពីបញ្ហាលុយកាក់សម្រាប់ទិញដីនោះ ខ្លួនគ្រាន់តែជាអ្នកជូនក្រុមការងារទៅទិញដីតែប៉ុណ្ណោះ ដោយប្រជាពលរដ្ឋលក់ដោយខ្លួនគាត់ផ្ទាល់ ដោយមានមេភូមិចាំចុះហត្ថលេខានៅពេលនោះតែម្តងបើមេភូមិមិនចុះហត្ថលេខាក្រុមការងារមិនហ៊ានប្រគល់លុយនោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] យឿត។ ឈ្មោះ [redacted] នឿត ឈ្មោះ [redacted] យឿត និងខ្លួនគឺធ្វើសកម្មភាពដូចតែគ្នា ដោយឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] យឿត មានតួនាទីដើរសួរដីអ្នកស្រុក ដែលរស់នៅភូមិសំបួរ ចំណែកខ្លួនដើរសួរនៅភូមិអំពិល។ ឈ្មោះ [redacted] ប៊ូឡាស់ ឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ គាត់មិនបានឱ្យកំរៃថ្លៃខ្លួនខំរកប្រជាពលរដ្ឋដែលលក់ដីនោះទេ ប៉ុន្តែប្រសិនបើខ្លួនចង់បានលុយទាល់តែធ្វើពាក្យខ្ចីពួកគាត់នឹងឱ្យខ្លួនខ្ចី ហើយខ្លួនធ្លាប់ខ្ចីពីពួកគាត់ចំនួន០៦ លើក សរុបទឹកប្រាក់ខ្ចីចំនួនប្រហែល៧០០ (ប្រាំពីររយ) ដុល្លាអាមេរិក ទឹកប្រាក់ខ្ចីនេះមិនស្មើនឹងការដែលខ្លួនចំណាយថ្លៃដើររកអ្នកលក់ដីឱ្យគាត់នោះទេ ពីព្រោះចំណាយថ្លៃសាំង និងថ្លៃចំណាយផ្សេងៗលើសនោះទៅទៀត។ បន្ទាប់ពីតុលាការកោះអញ្ជើញខ្លួនមកឆ្លើយបំភ្លឺ ខ្លួនបានសួរទៅមេឃុំសំបួរ គាត់បានឆ្លើយថាខាងក្រុមហ៊ុននោះគាត់ទិញបានដីចំនួន៨១ (ប៉ែតសិបមួយ) ហិចតា កន្លះ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នឿត បានឆ្លើយថា: ខ្លួនមិនស្គាល់ឈ្មោះ [redacted] ឆន នោះទេ។ ខ្លួនស្គាល់តែឈ្មោះ [redacted] ប៊ូឡាស់ និងឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ មូលហេតុដែលខ្លួនស្គាល់ឈ្មោះទាំងនេះដោយសារពួកគាត់ជាក្រុមការងារចុះទៅទិញដី ដោយពួកគាត់ឈរជើងនៅក្នុងភូមិអំពិល ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដោយពួកគាត់រកទិញដីចំនួន៣ចំណុច ដោយចំណុចទី១ ទិញ២៥ហិចតា ស្ថិតនៅភូមិសន្លួន ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ចំណុចទី២ ចំនួន៤១ហិចតា ស្ថិតនៅភូមិអំពិល ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប និងចំណុចទី៣ ចំនួន៧៥ ហិចតា ស្ថិតនៅភូមិគោកចាស់ ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ក្រោយមកឈ្មោះ [redacted] ប៊ូឡាស់, និងឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ឆាក់ ពួកគាត់បានមករកខ្លួន ឱ្យជួយរកទិញដី ដោយពួកគាត់ស្គាល់ខ្លួន

តាមរយៈបងប្អូនខ្លួនដែររស់នៅក្រុងសៀមរាបដោយឱ្យខ្លួនជួយរកដី ហើយឱ្យតម្លៃខ្លួន១ (មួយ) ហិចតា តម្លៃ១០០(មួយរយ) ដុល្លាអាមេរិក ដោយពួកខ្លួនចែកគ្នាបួននាក់ មានឈ្មោះ [redacted]រាប ភេទប្រុស (ស្លាប់) ឈ្មោះ [redacted] យឿត ភេទប្រុស (ស្លាប់) និងឈ្មោះ[redacted] ភ្លន់ ភេទប្រុស ហើយលុយកំរៃជួយរកអ្នកលក់ដីនឹង គឺពួកគាត់មិនមែនឱ្យខ្លួនស្រួលៗទេ គឺពួកខ្លួនត្រូវធ្វើពាក្យសុំខ្ចី ទាល់តែពួកខ្លួនជួយរកទិញដីនៅក្នុងភូមិខាងលើនេះបានគ្រប់ចំនួន ទើបពួកគាត់ទូរទាត់ឱ្យ។ ហើយពេលនោះខ្លួនក៏បានលក់ដីរបស់ខ្លួនដោយផ្ទាល់ខ្លួនផងដែរ ដោយលក់ចំនួន៨០ (ប៉ែតសិប) អា។ ចំពោះលុយកាក់ទិញដី ខ្លួនមិនដឹងទេពី បញ្ហាលុយកាក់សម្រាប់ទិញដីនោះ ខ្លួនគ្រាន់តែជាអ្នកជួយរកអ្នកលក់ដីជូនក្រុមការងារតែប៉ុណ្ណោះ ដោយប្រជាពលរដ្ឋលក់ដោយខ្លួនគាត់ផ្ទាល់ ដោយមានមេភូមិចាំចុះហត្ថលេខានៅពេលនោះតែម្តង បើមេភូមិមិនចុះហត្ថលេខាក្រុមការងារគាត់មិនហ៊ានប្រគល់លុយនោះទេ ហើយប្រគល់លុយពួកគាត់សុទ្ធតែបានថតជារូបភាពផងដែរ។ ខ្លួនស្គាល់ឈ្មោះ [redacted]ភ្លន់ និងឈ្មោះ [redacted]យឿត។ ឈ្មោះ [redacted]ភ្លន់ ឈ្មោះ[redacted] យឿត និងខ្លួនគឺធ្វើសកម្មភាពដូចតែគ្នាជាមួយខ្លួនដែរការងារតែមួយ ដោយឈ្មោះ[redacted]ភ្លន់ គាត់ដើរសួរអ្នកលក់នៅភូមិអំពិល និងឈ្មោះ [redacted] យឿត ដើរសួរអ្នកលក់នៅភូមិសំបួរ ចំណែកខ្លួនសួរនៅភូមិសំបួរផងដែរ។

-តាមអំណានចម្លើយលោក [redacted]លីថៃ ជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ឆន បានឆ្លើយថា: ខ្លួនជាមេធាវីតំណាងដោយអាណត្តឈ្មោះ [redacted] ឆន បានដាក់ពាក្យបណ្តឹងឈ្មោះ [redacted] ឆាក់ ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] យឿត ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] ប៊ូឡាស់ ភេទប្រុស អាយុ៤៧ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] នៀត ភេទប្រុស អាយុ៦១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ, ឈ្មោះ [redacted]ផៃ ភេទប្រុស អាយុ៤២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ[redacted]ភ្លន់ ភេទប្រុស អាយុ៦២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ពីបទ: ឆបោក និងរំលោភលើទំនុកចិត្ត ចាប់ពីឆ្នាំ ២០០៨ ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ នៅក្នុងឆ្នាំ២០០៨ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ឆន បានទិញដីពីឈ្មោះ [redacted] ឆាក់ ឈ្មោះ [redacted] យឿត ឈ្មោះ [redacted] ប៊ូឡាស់, ឈ្មោះ[redacted]នៀត, ឈ្មោះ [redacted]ផៃ និងឈ្មោះ [redacted]ភ្លន់ ចំនួន២២១ (ពីររយម្ភៃមួយ) ហិចតា មានទីតាំងស្ថិតនៅភូមិសំបួរ ភូមិគោកចាស់ និងភូមិសន្លន ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលក្នុងមួយហិចតាមានតម្លៃ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ហើយកូនក្តីរបស់ខ្លួនបានប្រគល់ប្រាក់ឱ្យទៅអ្នកទាំងប្រាំមួយនាក់នោះចំនួន៣៧៥,១៨៣ (សាមសិបប្រាំពីរម៉ឺន ប្រាំពាន់មួយរយប៉ែតសិបបី) ដុល្លាអាមេរិក គ្រប់ចំនួនថ្លៃដីទាំងអស់។ នៅពេលធ្វើការទិញដីនោះដែរអ្នកទាំងប្រាំមួយនាក់នេះ បាននាំកូនក្តីរបស់ខ្លួនទៅមើលទីតាំងដី និងបានបង្ហាញនូវគំរូសបង្ហាញរូបរាងដី និងគណនាក្រឡាផ្ទៃដី ស្ថិតនៅភូមិសន្លន ភូមិសំបួរ ភូមិគោកចាស់ និងភូមិអំពិល ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលវាស់វែងដោយលោក រ៉ែម គឹមសាន ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ មានចំនួន០២ ប្លង់ និងមានឯកសារផ្ទេរសិទ្ធិដីមួយចំនួន។ បន្ទាប់ពីធ្វើការប្រគល់ប្រាក់ថ្លៃដី កូនក្តីរបស់ខ្លួនបានឱ្យអ្នកទាំងប្រាំមួយនាក់នេះទៅបង្ហាញទីតាំងដីជាក់ស្តែង តែនាក់ទាំងប្រាំមួយនាក់នោះពុំព្រមទៅបង្ហាញទីតាំងដីទេ ដោយសន្យាថាថ្ងៃនេះថ្ងៃនោះរហូត ហើយឱ្យកូនក្តីរបស់ខ្លួនរង់ចាំមកដល់ពេលនេះកូនក្តីរបស់ខ្លួនបានទទួលដីចំនួនជាក់ស្តែងបានតែចំនួន៦៤ (ហុកសិបបួន) ហិចតា តែប៉ុណ្ណោះនៅខ្វះចំនួន១៥៧ (មួយរយហាសិបប្រាំពីរ) ហិចតា ទៀត គិតជាទឹកប្រាក់ស្មើនឹងចំនួន

២៦៦,៣៨៣ (ម្ភៃប្រាំមួយម៉ឺន ប្រាំមួយពាន់បីរយប៉ែតសិបបី) ដុល្លារអាមេរិក ដែលអ្នកទាំងប្រាំមួយនាក់មិនបានធ្វើការប្រគល់ដីឱ្យកូនក្តីរបស់ខ្លួនបានគ្រប់ចំនួនទឹកប្រាក់ដែលកូនក្តីរបស់ខ្លួនបានប្រគល់នោះទេ មិនដឹងថាអ្នកទាំងប្រាំមួយនាក់យកប្រាក់កូនក្តីរបស់បានទៅធ្វើអ្វីនោះទេ បានតែឯកសារតែដីជាក់ស្តែងពុំមាន។ នៅក្នុងរឿងនេះ មានឯកសារជាភស្តុតាងដែលខ្លួនបានដាក់ភ្ជាប់មកជាមួយពាក្យបណ្តឹងទាំងអស់។ នៅពេលនេះ ខ្លួនតំណាងដោយអាណត្តិឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ឆន ប្តឹងសុំលោកព្រះរាជអាជ្ញា ផ្តន្ទាទោសជនល្មើសតាមច្បាប់, ប្តឹងទាមទារសំណងការខូចខាតបង់ជាប្រាក់ចំនួន២៦៦,៣៨៣ (ម្ភៃប្រាំមួយម៉ឺន បីពាន់ប្រាំបីរយប៉ែតសិបបី) ដុល្លារអាមេរិក និងទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន១០០០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្នុងនាមតំណាងអយ្យការ សូមឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ភួន់ និងឈ្មោះ [redacted] នឿត បានធ្វើសេចក្តីសន្និដ្ឋានថា: ក្នុងរឿងនេះដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទពុំបានជួបតទល់គ្នាឡើយ ប៉ុន្តែនៅតំណាក់កាលចៅក្រមស៊ើបសួរពួកគាត់បានចូលមកឆ្លើយ និងត្រូវបានតុលាការដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យ។ ហេតុនេះសូមតុលាការឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឆាក់ បានធ្វើសេចក្តីសន្និដ្ឋានថា:

១.កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ឆាក់ ភេទប្រុស អាយុ៦៣ ឆ្នាំ មុខរបរ ទាហាន ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះតាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៨៨៧ ពស.ព្រស/ច ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ចោទពីបទ ឆបោក ប្រព្រឹត្តនៅចំណុចស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២.តាមពាក្យបណ្តឹង និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅគ្រប់ដំណាក់កាលនីតិវិធីបានប្តឹងចោទប្រកាន់កូនក្តីឈ្មោះ [redacted] ឆាក់ ពីបទ ឆបោក ប្រព្រឹត្តកាលពីអំឡុងឆ្នាំ២០០៨ តាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៣.តំណាងអយ្យការបានបើកការស៊ើបសួរ តាមដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥០៤/២០១៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ចោទប្រកាន់កូនក្តីឈ្មោះ [redacted] ឆាក់ ពីបទ ឆបោក ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប <u>កាលពីអំឡុងឆ្នាំ២០០៨</u> តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៤.តាមចម្លើយរបស់កូនក្តីឈ្មោះ [redacted] ឆាក់ និងចម្លើយរបស់ជនជាប់ចោទផ្សេងទៀតឈ្មោះ [redacted] នឿត, ឈ្មោះ [redacted] ភួន់ បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី មានលក្ខណៈស៊ីសង្វាក់គ្នា សបញ្ជាក់ថា អង្គហេតុដែលបានកើតឡើង គឺ<u>កាលពីអំឡុងឆ្នាំ២០០៨</u>។



Scanned with CamScanner

៥.សរុបមក យើងអាចសន្និដ្ឋានបានថា អង្គហេតុដែលប្តឹងចោទប្រកាន់ពីសំណាក់ដើមបណ្តឹង, តំណាងអយ្យការ និងចៅក្រមស៊ើបសួរ គឺអង្គហេតុបានកើតឡើងតាំងពីអំឡុងឆ្នាំ២០០៨ មកម្លេះ នេះបើយោងតាមមូលដ្ឋានចំណុច១, ២, ៣ និង៤ ខាងលើ។

៦.កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ខ្លួនបានដាក់ពាក្យស្នើសុំលើកលែងចោទប្រកាន់ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ជូនចៅក្រមស៊ើបសួរ ស្នើសុំសម្រេចលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ឆាក់ ភេទប្រុស អាយុ៦៤ ឆ្នាំ ពីបទ ឆបោក ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ផ្អែកលើមូលហេតុ ការផុតរលត់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា។ ប៉ុន្តែចៅក្រមស៊ើបសួរនៅតែបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ឆាក់ ទៅជំនុំជម្រះ តាមដីការសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៨៨៧ ពស.ព្រស/ធ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។

៧.មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិអំពីការរលត់នៃបណ្តឹងអាជ្ញា៖

មូលហេតុនៃការរលត់នៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖

ចំណុចទី២. ការផុតអាជ្ញាយុកាល។

៨.មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិអំពីអាជ្ញាយុកាលនៃបទល្មើស៖

ចំណុចទី២. -៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម។

៩.មាត្រា៤៧ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិអំពីនិយមន័យនៃបទមជ្ឈិម៖

អតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងមានរយៈពេល លើសពី ៦(ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង៥ (ប្រាំ) ឆ្នាំ។

១០.មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិអំពីទោសដែលត្រូវអនុវត្តចំពោះបទឆបោក៖

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ។

១១.ផ្អែកតាមមូលដ្ឋាននៃចំណុច៦, ៧, ៨, ៩ និង១០ ខាងលើ សបញ្ជាក់ថា អំពើឆបោក ដែលចោទប្រកាន់គឺជាបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសពី៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ ហើយបទល្មើសនេះមានអាជ្ញាយុកាលត្រឹម៥ (ប្រាំ) ឆ្នាំ ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមទៀតបានទេ ឬត្រូវតែបញ្ឈប់។

១២.ស្នើសុំប្រាន់ចោល ការប្តឹងចោទប្រកាន់ តាមពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] របស់តំណាងអយ្យការ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១៥០៤/២០១៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ និងរបស់ចៅក្រមស៊ើបសួរ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦៨៨៧ ពស.ព្រស/ធ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។

១៣.សរុបសេចក្តីមកឃើញថា អំពើ ឬអង្គហេតុដែលប្តឹងចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] ឆាក់ ពីបទ ឆបោក គឺកើតឡើងតាំងពីឆ្នាំ២០០៨ ដូច្នេះ បើគិតអាជ្ញាយុកាលនៃបទល្មើស គឺបានផុតអាជ្ញាយុកាលនៃបទល្មើសទៅហើយ នេះបើយោងតាមមាត្រា៧ និងមាត្រា១០ នៃក្រមនិតិវិធីព្រហ្មទណ្ឌ និងមាត្រា៤៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។ ផ្អែកតាមមូលដ្ឋាននេះ បទចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] ឆាក់ មិនអាចចាប់ផ្តើមទៀតបានទេ និងត្រូវតែបញ្ឈប់។



Scanned with CamScanner

១៤.ម្យ៉ាងវិញទៀត បើផ្អែកតាមអង្គហេតុដែលដើមបណ្ដឹងរៀបរាប់ក្នុងពាក្យបណ្ដឹង ចម្លើយគ្រប់ដំណាក់កាលនីតិវិធី និងអង្គហេតុដែលចោទប្រកាន់ របស់តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ឃើញថា គឺជាកិច្ចសន្យាទិញលក់អចលនវត្ថុ(ដី) ដែលមានទីតាំងស្ថិតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលជាអង្គហេតុវិវាទផ្នែករដ្ឋប្បវេណី ដែលត្រូវដោះស្រាយតាមក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។

១៥.គ្មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឆាក់ ភេទប្រុស អាយុ៦៣ ឆ្នាំ មុខរបរ ទាហាន ជាប់ចោទពីបទ **ឆបោក** ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**<u>សំណូមពរ៖</u>**

ក.ច្រានចោលពាក្យបណ្ដឹង ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] និងការទាមទារទាំងអស់ទុកជាអាសារបង់។

ខ.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឆាក់ មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ហើយជនជាប់ចោទក៏គ្មានកំហុសដែរ ដូច្នេះ ស្នើសុំឱ្យជនជាប់ចោទឈ្មោះ [redacted] ឆាក់ ភេទប្រុសអាយុ៦៣ ឆ្នាំ មុខរបរ ទាហាន បានរួចខ្លួនពីបទចោទ ពីបទ **ឆបោក** ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆន បានធ្វើសេចក្ដីសន្និដ្ឋានថា: ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ[redacted] ឆន ជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងរឿងនេះកូនក្ដីរបស់ខ្លួនប្ដឹងពីឈ្មោះ [redacted] ឆាក់, ឈ្មោះ[redacted] ភ្លន់, ឈ្មោះ [redacted] នឿត, ឈ្មោះ[redacted] យឿត, ឈ្មោះ [redacted] ប៉ូឡាស់ និងឈ្មោះ [redacted] ផៃ បានទទួលទិញដីឱ្យកូនក្ដីរបស់ខ្លួនចំនួន១៥៧ (មួយរយហាសិបប្រាំពីរ) ហិចតា ប៉ុន្តែពួកគេទិញបានតែចំនួន៦៤ (ហុកសិបបួន) ហិចតា ហើយក្រោយមក ទើបដឹងថាពួកអ្នកទាំងប្រាំមួយនោះមានដីតែចំនួន៦៤ (ហុកសិបបួន) ហិចតា ហើយមួយចំនួនទៀត គឺពួកគាត់ពុំមានដីពិតប្រាកដទេ។ ក្នុងរឿងនេះកូនក្ដីរបស់ខ្លួនបានប្រគល់ប្រាក់ឱ្យពួកគាត់ ដែលមានកំណត់ហេតុប្រគល់ទទួលទៀតផង ប៉ុន្តែជនជាប់ចោទបានធ្វើការដោះសារ ក្នុងរឿងនេះខ្លួនបានដាក់ភស្តុតាង និងឯកសារប្រគល់ទទួលប្រាក់មានស្នាមមេដៃពួកគាត់។ ហេតុនេះសូមសំណូមពរឱ្យតុលាការផ្ដន្ទាទោស និងបង់ប្រាក់ឱ្យកូនក្ដីរបស់ខ្លួន និងធ្វើការនាំខ្លួន និងទាមទារសំណងខាតបង់ចំនួន២៦.៦៣៨៣ (ម្ភៃប្រាំមួយម៉ឺន ប្រាំមួយពាន់បីរយប៉ែតសិបបី) ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន១០.០០០០ (ដប់ម៉ឺន) ដុល្លាអាមេរិក។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យភស្ដុតាង និងឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១- កាលពីអំឡុង២០០៨ ពិតជាមានករណី **ឆបោក** ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ឆាក់**, ឈ្មោះ [redacted] **ភ្លន់**, ឈ្មោះ [redacted] **នឿត**, ឈ្មោះ [redacted] **យឿត**, ឈ្មោះ [redacted] **ប៊ុំឡាស់** និងឈ្មោះ [redacted] **ផៃ** ប្រាកដមែន។

២-ជនជាប់ចោទពិតជាមានចេតនាទុច្ចរិត ក្នុងការកែបំបាត់នូវទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងត្រូវផ្ដន្ទាទោស។

៣-ជនជាប់ចោទជានីតិជន ហើយពុំមានសញ្ញាណណាមួយនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយដូច្នេះ ជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។

៤-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់របៀបរៀបរយ សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៥-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ការពិតពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ឆាក់** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] **ភ្លន់** ភេទប្រុស អាយុ៦៤ ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] **នឿត** ភេទប្រុស អាយុ៥៨ ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] **យឿត** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] **ប៊ុំឡាស់** ភេទប្រុស អាយុ៤៧ ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ផៃ** ភេទប្រុស អាយុ៤២ ឆ្នាំ ជនជាតិខ្មែរ ពីបទ: **ឆបោក** ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោស

ក/ឈ្មោះ [redacted] **ឆាក់** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ **(មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តព្យួរ** និងពិន័យជាប្រាក់ចំនួន**២.០០០.០០០ (ពីរលាន)** រៀល។

ខ/ឈ្មោះ [redacted] **ភ្លន់** ភេទប្រុស អាយុ៦៤ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ **(មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តព្យួរ** និងពិន័យជាប្រាក់ចំនួន**២.០០០.០០០ (ពីរលាន)** រៀល។

គ/ឈ្មោះ [redacted] **នឿត** ភេទប្រុស អាយុ៥៨ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ **(មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តព្យួរ** និងពិន័យជាប្រាក់ចំនួន**២.០០០.០០០ (ពីរលាន)** រៀល។



Scanned with CamScanner

ឃ/ឈ្មោះ [redacted] **ឃឿត** ភេទប្រុស អាយុ៦៣ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀល។

ង/ឈ្មោះ [redacted] **ប៊ុំឡាស់** ភេទប្រុស អាយុ៤៧ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀល។

ច/ឈ្មោះ [redacted] **ផៃ** ភេទប្រុស អាយុ៤២ ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀល។

ពីបទ: **ឆបោក** ប្រព្រឹត្តនៅស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា<u>៣៧៧</u> និងមាត្រា<u>៣៧៨</u> នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទទាំងអស់រួមគ្នាសងសំណងការខូតខាតទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆន ចំនួន២៦.៦៣៨៣ (ម្ភៃប្រាំមួយម៉ឺន ប្រាំមួយពាន់បីរយប៉ែតសិបបី) ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន២០.០០០.០០០ (ម្ភៃលាន) រៀល។

៣.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] **ឃឿត**, ឈ្មោះ [redacted] **ប៊ុំឡាស់** និងឈ្មោះ [redacted] **ផៃ** ផ្អែកតាមមាត្រា<u>៣៥៣</u> នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និង ត្រា [redacted] | ហត្ថលេខា និង ត្រា [redacted] |

---

| | |
| --- | --- |
| **បានឃើញ** | " បានចម្លងត្រឹមត្រូវតាមច្បាប់ដើម " |
| **ចៅក្រមជំនុំជម្រះ** | នៅថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ |
| [redacted] | សៀមរាប ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ |
| | **ក្រឡាបញ្ជីសវនាការ** |
| | [redacted] |



Scanned with CamScanner